ការត្រួតពិនិត្យរកជាតិសំណ
នៅក្នុងផ្ទះ និងជុំវិញផ្ទះរបស់អ្នក

អ្នកមិនអាចមើលឃើញជាតិសំណបានទេ ប៉ុន្តែជាតិសំណអាចមាននៅគ្រប់ទីកន្លែងនៅក្នុងផ្ទះ និងក្រៅផ្ទះរបស់អ្នក។ ជាតិសំណអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពកូនរបស់អ្នកតាមមធ្យោបាយជាច្រើន។ កុមារជាច្រើនដែលមានជាតិសំណពុលក្នុងខ្លួនមិនមានបង្ហាញរោគសញ្ញា ឬអាការៈឈឺណាមួយទេ។ តើអ្នកមានប្រភពជាតិសំណណាមួយនៅក្នុងផ្ទះ ឬនៅជុំវិញផ្ទះរបស់អ្នកដែរឬទេ? សូមប្រើបញ្ជីខាងក្រោមដើម្បីធ្វើការត្រួតពិនិត្យ៖

ថ្នាំលាប

- [ ] សូមឱ្យកុមារស្ថិតនៅឱ្យឆ្ងាយពីថ្នាំលាបដែលមានរបករលាត់ ឬមានស្នាមប្រេះស្រាំ។

ផ្ទះដែលបានសាងសង់នៅមុនឆ្នាំ 1978 ត្រូវបានសន្មតថាជាផ្ទះមានថ្នាំលាបមានជាតិសំណ ដែលប្រេះស្រាំ ឬរបករលាត់ចេញ ហើយក្លាយជាធូលី។ កុមារអាចញ៉ាំកំទេចថ្នាំលាប ឬប៉ះពាល់ធូលីដែលនៅលើប្រដាប់លេងរបស់ពួកគេ។

ធូលី

- [ ] សូមប្រើកន្សែងសើមនៅពេលជូតសម្អាតកន្លែងផ្សេងៗដើម្បីកុំឱ្យមានធូលីហុយ។

ធូលីមានជាតិសំណអាចប្រមូលផ្តុំនៅក្នុងផ្ទះរបស់អ្នកពីថ្នាំលាបដែលមានជាតិសំណ ឬពីការបំពុលខ្យល់ពីតំបន់ឧស្សាហកម្ម ឬអាកាសយានដ្ឋាន។ ធូលីមានជាតិសំណនេះក៏អាចត្រូវបានគេនាំចូលមកក្នុងផ្ទះដងដែរ ប្រសិនបើមាននរណាម្នាក់ធ្វើការងារ ឬធ្វើសកម្មភាពប្រចាំថ្ងៃដែលពាក់ព័ន្ធនឹងជាតិសំណនេះ។

ដីកខ្វក់

- [ ] សូមលាងសម្អាតដៃកូនរបស់អ្នកឱ្យបានញឹកញាប់ ហើយបិទបាំងរាលដីកខ្វក់ដោយដាំរុក្ខជាតិ ស្មៅ គ្របសំបកឈើ ឬក្រួសពីលើ។

ជាតិសំណអាចស្ថិតនៅក្នុងដីកខ្វក់ពីប្រភពបរិស្ថានជាច្រើន។ ប្រសិនបើកុមារលេងដីកខ្វក់ ធូលីមានជាតិសំណអាចគោងជាប់នៅលើដៃរបស់ពួកគេ។

ទឹក

- [ ] សូមប្រើម៉ាស៊ីនចម្រោះទឹកដែលមានការបញ្ជាក់ថាអាចចម្រោះយកជាតិសំណចេញពីទឹកបាន។
- [ ] សូមប្រើទឹកត្រជាក់សម្រាប់ពិសា ចម្អិនអាហារ និងលាយទឹកដោះគោឱ្យទារក។

ផ្ទះមួយចំនួនអាចមានជាតិសំណនៅក្នុងទុយោទឹក ឬឧបករណ៍ភ្ជាប់ទឹកដែលមានជាតិសំណ ហើយវាអាចចូលទៅក្នុងទឹករបស់អ្នកបាន។ សូមទាក់ទងទៅក្រុមហ៊ុនផ្គត់ផ្គង់ទឹករបស់អ្នកសំរាប់ព័ត៌មានបន្ថែម។

គ្រឿងសំអាង
និងការព្យាបាលតាមប្រពៃណី

- [ ] សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកមុនពេលប្រើគ្រឿងសំអាង ម្សៅ ឬការព្យាបាលតាមបែបប្រពៃណីណាមួយមានដូចជាៈ ខោល (kohl) សួរ៉ាម៉ា (surma) សិនដួរ (sindoor) អាហ្សាកន (azarcon) ក្រេតា (greta) និង ផេឡួអា (pay-loo-ah)។

ម្ហូបអាហារ
និងគ្រឿងទេសមួយចំនួន

- [ ] សូមកុំប្រើអាហារ និងគ្រឿងទេសនាំចូល ដែលអាចមានជាតិសំណ មានដូចជា កណ្តូប (កណ្តូបសម្ងួត) ម្ទេសក្រៀម អំពិល និងរមៀត។

កូនសណ្តូននេសាទត្រី
និងគ្រាប់កាំភ្លើង

- [ ] សូមឱ្យកុមារស្ថិតនៅឱ្យឆ្ងាយពីកូនសណ្តូននេសាទត្រីដែលមានជាតិសំណ ឬគ្រាប់កាំភ្លើងដែលមានជាតិសំណ និងសំបកគ្រាប់កាំភ្លើងដែលមានជាតិសំណ។

ចានឆ្នាំង
និងសម្ភារៈផ្ទះបាយ

- [ ] សូមកុំប្រើចានចាស់ៗ ចានផលិតដោយដៃ ឬចានដែលនាំចូលមកពីខាងក្រៅសហរដ្ឋអាមេរិក ប្រសិនបើសម្ភារៈទាំងអស់នោះមិនត្រូវបានគេធ្វើតេស្តរកជាតិសំណទេ។

CDPH
California Department of Public Health

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ go.cdph.ca.gov/LeadFreeKids ឬទាក់ទង៖

ខែធ្នូ ឆ្នាំ 2024 · © 2024 ក្រសួងសុខាភិបាលសាធារណៈរដ្ឋកាលីហ្វ័រញ៉ា